សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the
Promotion and Defense
of
Human Rights




# ការនាំឱ្យមានចំណាកស្រុក៖

## បទពិសោធន៍នៃភូមិមួយអំពីបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងចំណាកស្រុកឆ្លងដែន


របាយការណ៍សង្ខេប
ចេញផ្សាយ ខែឧសភា ឆ្នាំ២០២០

# ការនាំឱ្យមានចំណាកស្រុក៖
## បទពិសោធន៍នៃភូមិមួយអំពីបំណុល
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងចំណាកស្រុកឆ្លងដែន

របាយការណ៍សង្ខេបចេញផ្សាយ ខែឧសភា ឆ្នាំ២០២០


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


ខ្លឹមសារសង្ខេប ទំព័រ១

សារតា ទំព័រ៤

វិធីសាស្រ្ត ទំព័រ៦

ការរកឃើញនៃការសិក្សា ទំព័រ៧

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ទំព័រ១០

ឧបសម្ព័ន្ធទី១៖ ការផ្តល់មូលនិធិដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាជារូបិយវត្ថុបាតរបស់ប្រទេសថៃ ទំព័រ១១




ពលករចំណាកស្រុកត្រលប់មកពីប្រទេសថៃ (រូបភាព ទទួលបានពីពលករចំណាកស្រុក)

*ការស្រាវជ្រាវនេះ គឺមិនត្រូវបានធ្វើឡើងក្នុងគោលបំណងតំណាងឱ្យតួលេខទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬការរកឃើញពីអតិថិជនទាំងអស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជានោះទេ។ របាយការណ៍សង្ខេបនេះ គ្រាន់តែត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីបញ្ហាមួយចំនួនដែលអ្នកស្រាវជ្រាវបានរកឃើញនៅតាមតំបន់គោលដៅ ដូចជាការចំណាកស្រុកជាដើម ដែលធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាកាន់តែធ្លាក់ចុះ និងធ្វើឱ្យភាពក្រីក្រនៅកម្ពុជាកាន់តែកើនឡើង។*

*របាយការណ៍សង្ខេបនេះ គឺជារបាយការណ៍លើកទីពីរនៃរបាយការណ៍មួយចំនួនទៀតរបស់អង្គការ លីកាដូ អំពីឥណទានខ្នាតតូចនៅកម្ពុជា។*

# ខ្លឹមសារសង្ខេប

វិស័យមីក្រូហិរញ្ញវត្ថុដ៏ធំសម្បើមនៅកម្ពុជា បានពឹងផ្អែកនិងជួយជំរុញឱ្យមានការធ្វើចំណាកស្រុករបស់ពលរដ្ឋកម្ពុជាទៅកាន់ប្រទេសថៃ ដើម្បីជួយទ្រទ្រង់កម្ចីខ្នាតតូចដែលមានអត្រាគិតជាមធ្យមខ្ពស់បំផុតនៅលើពិភពលោក ។ នៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ការរីករាលដាលនៃបញ្ហាវីរុសកូវីដ ១៩ (Covid-19) នៅក្នុងតំបន់ ធ្វើឱ្យពលករចំណាកស្រុក ជាង៩០.០០០នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ។[១] ពលករទាំងអស់នេះ

## "ប្រសិនបើយើងមានកូនធ្វើការនៅប្រទេសថៃ យើងអាចខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុបាន"

មិនត្រឹមតែត្រូវប្រឈមមុខទៅនឹងការលំបាកក្នុងការសម្របខ្លួនជាមួយជីវភាពរស់នៅប្រចាំថ្ងៃក្នុងស្រុកវិញនោះទេ[២] ប៉ុន្តែប្រវត្តិដែលអ្នកទាំងនេះវិលត្រឡប់មកស្រុកកំណើតនៅក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃវីរុសកូវីដ១៩ និងការមិនទទួលបានឱកាសការងារនៅក្នុងប្រទេសកំណើត បានធ្វើឱ្យអ្នកទាំងនេះ ជួបបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ។ បញ្ហាទាំងនេះអាចជាមូលដ្ឋាន ដែលបង្កទៅជាវិបត្តិផ្នែកសិទ្ធិមនុស្ស ដែលអាចធ្វើប្រជាពលរដ្ឋកម្ពុជារាប់សែននាក់ឆាប់បាត់បង់ប្រភពចំណូល និងគ្មានលទ្ធភាពសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលភាគច្រើននៃបំណុលទាំងនេះ មានការយកប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានាបំណុល (បញ្ចាំ) ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះបានទទូចឱ្យខ្ញុំយកប្រាក់កម្ចីបន្ថែម ប៉ុន្តែខ្ញុំមិនចង់ទទួលប្រាក់កម្ចីបន្ថែមទៀតទេ។

នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ មុនការរីករាលដាលនៃវីរុសកូវីដ១៩ អ្នកស្រាវជ្រាវរបស់អង្គការលីកាដូ បានធ្វើការស្ទង់មតិអំពីទំនាក់ទំនងរវាងការធ្វើចំណាកស្រុក និងមីក្រូហិរញ្ញវត្ថុនៅក្នុងភូមិមួយ[៣]ស្ថិតក្នុងខេត្តបន្ទាយមានជ័យ ដែលជាប់ព្រំដែនប្រទេសកម្ពុជា-ថៃ។ការស្ទង់មតិនេះប្រើប្រាស់ទម្រង់សំណួរបើក និងផ្តោតជាសំខាន់ទៅលើផលប៉ះពាល់ និងទំនាក់ទំនងរវាងការធ្វើចំណាកស្រុក និងបំណុលមីក្រូហិរញ្ញវត្ថុទៅលើជីវភាពរបស់អ្នកភូមិ និងក្រុមគ្រួសាររបស់អ្នកទាំងនោះ ដែលកំពុងរស់នៅក្នុងភូមិគោលដៅ ។

លទ្ធផលនៃការសិក្សានេះបង្ហាញថា បំណុលមីក្រូហិរញ្ញវត្ថុ គឺជា

## ទាំងប្រាក់ខ្ញុំ និងប្រាក់កូនខ្ញុំ ត្រូវយកទៅសងបំណុល ។ នៅពេលដែលខ្ញុំបានសងបំណុលមីក្រូហិរញ្ញវត្ថុរួច ខ្ញុំនឹងមិនឱ្យកូនខ្ញុំទៅធ្វើការនៅប្រទេសថៃទៀតនោះទេ ។

មូលហេតុចម្បងនាំឱ្យគ្រួសារភាគច្រើននៅក្នុងភូមិគោលដៅ ដែលចូលរួមក្នុងការសិក្សានេះ ធ្វើចំណាកស្រុក ។ ការរកឃើញនេះដូចគ្នាទៅនឹងការសិក្សារបស់អង្គការសហប្រជាជាតិ និងអ្នកស្រាវជ្រាវឯករាជ្យផ្សេងទៀត ដែលបានលើកឡើងថាបំណុលគឺជាមូលហេតុសំខាន់ ដែលនាំឱ្យមានចំណាកស្រុក និងការជួញដូរមនុស្ស។ ប្រជាពលរដ្ឋដែលផ្តល់បទសម្ភាសន៍ក្នុងភូមិគោលដៅភាគច្រើនរាយការណ៍ថា ពលករចំណាកស្រុកជួបប្រទះបញ្ហាជាច្រើនដូចជាការរំលោភបំពានពីសំណាក់អាជ្ញាធរ និងការរស់នៅឆ្ងាយពីក្រុមគ្រួសារជាដើម។ការសិក្សានេះក៏បង្ហាញផងដែរថា គ្រួសារនៃពលករចំណាកស្រុកនៅក្នុងភូមិនៅជិតព្រំដែនកម្ពុជា-ថៃ ទទួលរងការភ័យខ្លាច និងការធ្វើទុក្ខបុកម្នេញ បណ្តាលមកពីបំណុលមីក្រូហិរញ្ញវត្ថុរបស់អ្នកទាំងនេះដែលភាគច្រើននៃបំណុលទាំងនេះ មានដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានា ។ អ្នកភូមិដែលផ្តល់បទសម្ភាសន៍ភាគច្រើនរាយការណ៍ថា ការព្រួយបារម្ភខ្លាចបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិគឺជាលទ្ធផលដែលកើតឡើងដោយផ្ទាល់ពីបំណុលមីក្រូហិរញ្ញវត្ថុ។ អ្នកផ្តល់បទសម្ភាសន៍ភាគច្រើន បង្ហាញអារម្មណ៍អវិជ្ជមាន ចំពោះបំណុលមីក្រូហិរញ្ញវត្ថុ ខណៈអារម្មណ៍ដែលអ្នកទាំងនោះមានចំពោះការធ្វើចំណាកស្រុកមានលក្ខណៈផ្សេងៗគ្នា ។

នៅក្នុងករណីខ្លះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាអ្នកជួយជំរុញដោយផ្ទាល់

[១] រលេខនេះ ត្រូវបានលើកឡើងក្នុងសុន្ទរកថាថ្លែងដោយឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

[២] "Debt and the Migration Experience: Insights from South-East Asia", International Organization for Migration 2019 available at: https://publications.iom.int/system/files/pdf/debt_and_the_migration_experience_insights_from_southeast_asia_2.pdf

[៣] ឈ្មោះភូមិ និងរាល់ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកភូមិ ដែលផ្តល់បទសម្ភាសន៍ នឹងត្រូវរក្សាជាការសម្ងាត់

ឱ្យប្រជាពលរដ្ឋធ្វើចំណាកស្រុក តាមរយៈការមិនផ្តល់កម្ចីប្រសិនបើគ្រួសារគ្មានភស្តុតាងណាមួយបញ្ជាក់ថាមានសមាជិកគ្រួសារម្នាក់យ៉ាងតិច បានទៅធ្វើជាពលករចំណាកស្រុកនៅបរទេស ។ នៅក្នុងករណីខ្លះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់កម្ចីដល់ អ្នកភូមិសម្រាប់ចំណាយរត់ការដើម្បីបានទៅធ្វើការនៅបរទេស ដែលរួមមានទាំងចំណាយផ្លូវការ និងចំណាយក្រៅផ្លូវការផងដែរ ។

ទំនាក់ទំនងរវាង បំណុលមីក្រូហិរញ្ញវត្ថុ និងការចំណាកស្រុកគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជំនួយហិរញ្ញវត្ថុ ដែលផ្តល់ដោយម្ចាស់ជំនួយអន្តរជាតិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលរួមមានទាំងទីភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសក្នុងសហភាពអឺរ៉ុបមួយចំនួនផងដែរ។ស្ថាប័នរបស់រដ្ឋាភិបាលទាំងនេះផ្តល់ប្រាក់កម្ចីជារូបិយវត្ថុបាតរបស់ប្រទេសថៃ ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា (សូមមើលឧបសម្ព័ន្ធទី១) ។ បន្ទាប់មកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកបានផ្តល់កម្ចីជារូបិយវត្ថុបាតបន្ត ដល់ប្រជាពលរដ្ឋកម្ពុជា ក្រោយពីមានការធានាអះអាងថា អ្នកទាំងនោះមានប្រភពចំណូលពីសមាជិកគ្រួសារម្នាក់យ៉ាងតិច ដែលកំពុងធ្វើការជាពលករចំណាកស្រុកនៅប្រទេសថៃ ដើម្បីសងបំណុលត្រឡប់ទៅវិញ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានជួយជំរុញឱ្យមានការធ្វើចំណាកស្រុក និង ពឹងផ្អែកលើការធ្វើចំណាកស្រុកនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដើម្បីជួយទ្រទ្រង់អាជីវកម្មរបស់ខ្លួន ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងម្ចាស់ជំនួយអន្តរជាតិ មានគោលការណ៍ទំនួលខុសត្រូវប្រកបដោយក្រមសីលធម៌ ដើម្បីធានាថាយុទ្ធសាស្ត្រហិរញ្ញវត្ថុបច្ចុប្បន្ន នេះ នឹងមិនបណ្តាលឱ្យមានការធ្វើចំណាកស្រុកដើម្បីដោះបំណុល ការបាត់បង់ដីធ្លី ឬរងការរំលោភសិទ្ធិមនុស្សផ្សេងទៀតឡើយ ។

## ចំនួនពលករចំណាកស្រុកនៅចុង ឆ្នាំ ២០១៧




ទិន្នន័យពី CDB2017
រៀបចំដោយ អង្គការលីកាដូ

## ចំនួនពលករចំណាកស្រុកដែលបានវិលត្រលប់មកកម្ពុជាវិញនៅ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០




ទិន្នន័យពីក្រសួងមហាផ្ទៃ និង ក្រសួងព័ត៌មាន
រៀបចំដោយ អង្គការលីកាដូ

## មន្ត្រីឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រាប់ខ្ញុំថា "ប្រសិនបើអ្នកមិនមានប្រាក់គ្រប់គ្រាន់សងបំណុល រយៈពេលបីខែនោះទេ ពួកយើងនឹងរឹបអូសយកផ្ទះរបស់អ្នក" ខ្ញុំមិនដឹងថានឹងមានប្រាក់សងគេដោយរបៀបណានោះទេ

នៅក្នុងខែសីហា ឆ្នាំ២០១៩ អង្គការលីកាដូ និងសមាគមធាងត្នោត បានចេញផ្សាយរបាយការណ៍រួមមួយស្តីពីទំនាក់ទំនងរវាងវិស័យមីក្រូហិរញ្ញវត្ថុដ៏ធំសម្បើម និងការរំលោភសិទ្ធិមនុស្សដែលកើតឡើងដោយសារភាពជំពាក់បំណុលច្រើនលើសលុប ។ ទិន្នន័យដែលត្រូវបានធ្វើបច្ចុប្បន្នភាព បានបង្ហាញថា វិបត្តិនេះកាន់តែធ្ងន់ធ្ងរឡើងចាប់តាំងពីពេលដែលរបាយការណ៍នេះ ត្រូវបាន បោះពុម្ពផ្សាយជាសាធារណៈ ។ នៅបំណាច់ឆ្នាំ២០១៩ ប្រជាពលរដ្ឋកម្ពុជាអ្នកខ្ចីប្រាក់ជាង ២.៦ លាននាក់បានជាប់ជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាង ១០លានដុល្លាសហរដ្ឋអាមេរិក ដោយមានប្រាក់កម្ចីជាមធ្យម៣.៨០៤ដុល្លាសហរដ្ឋអាមេរិក ជាចំនួនដ៏ច្រើនបំផុតនៅក្នុងពិភពលោក និងខ្ពស់ជាងកម្រិតគួរឱ្យព្រួយបារម្ភណ៍ជាមធ្យមដែលមានត្រឹមតែ ៣.៣៧០ដុល្លាសហរដ្ឋអាមេរិកនៅចុងឆ្នាំ២០១៨។ បំណុលនេះ ដែលភាគច្រើនត្រូវយកប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានា នៅតែបន្តគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាពកម្មសិទ្ធិដីធ្លីរបស់គ្រួសារដែលជាប់បំណុល និងអាចបង្កទៅជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាលក្ខណៈប្រព័ន្ធ នៅទូទាំងប្រទេសកម្ពុជា ដោយរួមទាំងការចំណាកស្រុកដោយសារបំណុលផងដែរ ។

ការធ្វើចំណាកស្រុកបានកើនឡើងកាន់តែច្រើននៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅតំបន់ភាគពាយ័ព្យនៃប្រទេស ពោលគឺនៅតាមព្រំដែនប្រទេសកម្ពុជា-ថៃ ។ លទ្ធផលជាបឋមនៃជំរឿនក្នុងឆ្នាំ២០១៨បង្ហាញថាប្រ ជាពលរដ្ឋកម្ពុជាចំនួន ១.២៣លាននាក់ បានទៅធ្វើជាពលករនៅបរទេស ក្នុងនោះមានពលករចំនួន ១.១លាននាក់បានទៅធ្វើការនៅក្នុងប្រទេសថៃ ។ នេះគ្រាន់តែជាតួលេខដែលគិតចំពោះតែពលករដែលមានឯកសារត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ដូច្នេះចំនួនពលករចំណាកស្រុកជាក់ស្តែងអាចខ្ពស់ជាងនេះ ។ នៅក្នុងតួលេខផ្លូវការរបស់ រដ្ឋាភិបាលបានបញ្ជាក់ នៅក្នុងជំរឿនចុងក្រោយថា "កំណើនប្រជាជនកម្ពុជា បានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែ ការថយចុះនៃអត្រាកំណើត និងចំណាកស្រុកទៅបរទេស ជាពិសេសចំណាកស្រុកទៅប្រទេសជិតខាង ។"[៤]

ការសិក្សាក្នុងរយៈពេលកន្លងមកបានសនិដ្ឋានថា អត្រានៃកំណើនយ៉ាងឆាប់រហ័សនៃបំណុលមីក្រូហិរញ្ញវត្ថុ ពិតជាមានទំនាក់ទំនងផ្ទាល់ជាមួយការធ្វើចំណាកស្រុក ។ នៅក្នុងរបាយការណ៍របស់អង្គការចំណាកស្រុកអន្តរជាតិ ដែលចេញផ្សាយនៅក្នុងឆ្នាំ២០១៦បានរកឃើញថា ៤០.៦% នៃជនចំណាកស្រុកចាកចេញពីប្រទេសកម្ពុជា ដោយសារបំណុល ។[៥] នៅក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងបទឧក្រិដ្ឋនៅកម្ពុជា ដែលចេញផ្សាយនៅក្នុងឆ្នាំ២០១៧ បានសម្គាល់ឱ្យឃើញថាបំណុលមីក្រូហិរញ្ញវត្ថុជាកត្តាដែលជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាធ្លាក់ចូលទៅ

## បំណុលមីក្រូហិរញ្ញវត្ថុ មិនមែនជាប្រាក់ជំនួយទេ ប៉ុន្តែវាជាមធ្យោបាយរកប្រាក់ចំណូលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ ។ គ្រឹះស្ថានទាំងនោះមិនបានជួយកាត់បន្ថយចំនួនអ្នកចំណាកស្រុកនោះទេ ព្រោះអ្នកចំណាកស្រុកមួយចំនួនដែលជំពាក់ប្រាក់មីក្រូហិរញ្ញវត្ថុ ត្រូវធ្វើចំណាកស្រុកធ្វើការងាររកប្រាក់ដើម្បីដោះបំណុលមីក្រូហិរញ្ញវត្ថុនោះវិញ ។

ក្នុងភាពក្រីក្រ ។ របាយការណ៍នេះបានលើកឡើងថា "ទំនាក់ទំនងរវាងបំណុលមីក្រូហិរញ្ញវត្ថុ និងចំណាកស្រុក និងការជួញដូរមនុស្សពុំទាន់ត្រូវបានចងក្រងជាឯកសារ ឬសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ

[៤] "ជំរឿនប្រជាជនកម្ពុជានៅក្នុងឆ្នាំ២០១៩" វិទ្យាស្ថានជាតិស្ថិតិ, ទំ.៨, ឆ្នាំ២០១៨ ដែលអាចទាយយកបានតាមរយៈ
https://www.nis.gov.kh/nis/Census2019/Provisional%20Population%20Census%202019_English_FINAL.pdf

[៥] " Assessment Reportt: Profile of Returned Cambodian Migrant Workers," International Organization for Migration (IOM) Cambodia, p. 14, 2016, available at:
https://www.iom.int/sites/default/files/country/docs/IOM-AssessmentReportReturnedMigrants2016.pdf.

នៅឡើយទេ...ប៉ុន្តែបានបញ្ជាក់ពីភាពចាំបាច់នៃការយកចិត្តទុកដាក់ និងការសិក្សាវិភាគបន្ថែម ។"[៦]

ចំណាកស្រុក ដោយស្ម័គ្រចិត្តមិនមែនជាបញ្ហាសិទ្ធិមនុស្សនោះទេ ប៉ុន្តែទំនាក់ទំនងដ៏ស្មុគស្មាញរវាងចំណាកស្រុក ភាពក្រីក្រនិងបំណុល ជាពិសេសបំណុលមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា ធ្វើឱ្យចំណាកស្រុកដោយសារបំណុល ក្លាយជាទម្រង់នៃចំណាកស្រុកមានហានិភ័យខ្ពស់ និងធ្វើឱ្យពលករចំណាកស្រុកប្រឈមមុខនឹងហានិភ័យនៃការរំលោភបំពានធ្ងន់ធ្ងរ ។ របាយការណ៍របស់អង្គការចំណាកស្រុកអន្តរជាតិ ដែលចេញផ្សាយនៅក្នុងឆ្នាំ២០១៩ បានកត់សម្គាល់ឱ្យឃើញថា វាជាលក្ខណៈទូទៅរបស់មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ជាពិសេសការតម្រូវឱ្យតម្កល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាទ្រព្យធានាដ៏ពេញនិយម ដែលអាចនាំឱ្យមានការរំលោភសិទ្ធិមនុស្សដោយផ្ទាល់ ។ របាយការណ៍ដដែលបានបញ្ជាក់បន្ថែមទៀតថា "ការប្រឈមនឹង ការបាត់បង់ផ្ទះសម្បែង ឬដីធ្លី អាចក្លាយជាសម្ពាធខ្លាំងដល់កូនបំណុល ក្នុងការទូទាត់សងបំណុល ត្រឡប់ទៅវិញនិងធ្វើឱ្យកូនបំណុលដែលអាចក្លាយជាពលករចំណាកស្រុកនៅថ្ងៃមុខ សម្រេចចិត្តយកជម្រើសដែលមានហានិភ័យខ្ពស់ និងអាចប្រែក្លាយទៅជាភាពអាសន្ន ដែលកើតមានតែក្នុងទម្រង់នៃការផ្តល់កម្ចីបែបនេះ" ។[៧] ក្រុមអ្នកស្រាវជ្រាវរបស់អង្គការចំណាកស្រុកអន្តរជាតិ ក៏បានសង្កេតឃើញដែរថា ទីភ្នាក់ងារជ្រើសរើសពលករចំណាកស្រុកបានណែនាំ អតិថិជនរបស់ខ្លួនឱ្យទៅស្នើប្រាក់កម្ចីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដើម្បីធ្វើជាសោហ៊ុយ[៨] ដែលនេះជាទំនាក់ទំនងពីរផ្លូវស្រដៀងគ្នាទៅនឹងអ្វី ដែលអ្នកស្រាវជ្រាវរបាយការណ៍នេះ បានកត់សម្គាល់ គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាប់អតិថិជនរបស់ខ្លួនឱ្យបង្ហាញភស្តុតាងដែលបញ្ជាក់ថា យ៉ាងតិចណាស់មានសមាជិកគ្រួសារម្នាក់ កំពុងធ្វើការជាពលករចំណាកស្រុក មុនពេលទទួលបានឥណទាន ។

[៦] "Trafficking in Persons from Cambodia, Lao PDR and Myanmar to Thailand," United Nations Office on Drugs and Crime, p.18, August 2017, available at:
https://www.unodc.org/documents/southeastasiaandpacific//Publications/2017/Trafficking_in_persons_to_Thailand_report.pdf.

[៧] "Debt and the Migration Experience: Insights from South-East Asia," International Organization for Migration (IOM), p. 7, 2019, available at:
https://publications.iom.int/system/files/pdf/debt_and_the_migration_experience_insights_from_southeast_asia_2.pdf

[៨] Ibid, p. 24

# វិធីសាស្ត្រ

ដោយប្រើប្រាស់ទិន្នន័យរបស់រដ្ឋាភិបាល ក្រុមអ្នកស្រាវជ្រាវកំណត់យកភូមិចំនួន៩៣ នៅទូទាំងប្រទេស ដែលមានអត្រាបំណុលមីក្រូហិរញ្ញវត្ថុ និងអត្រាចំណាកស្រុកខ្ពស់ (លើសពី៤០% នៃមនុស្សពេញវ័យ) ។ ភាគច្រើននៃភូមិទាំងនេះ (ចន្លោះពី៨០ទៅ៩០ភូមិ) ស្ថិតនៅក្នុងខេត្តភាគពាយ័ព្យនៃប្រទេសកម្ពុជា ជិតព្រំប្រទល់ប្រទេសកម្ពុជា-ថៃ ។ ក្រុមអ្នកស្រាវជ្រាវជ្រើសរើសភូមិមួយនៅក្នុងខេត្តបន្ទាយមានជ័យដើម្បីធ្វើការសិក្សា ។ គោលបំណងនៃការសិក្សានេះគឺដើម្បីធ្វើការស្ទង់មតិទៅលើភាគរយខ្ពស់បំផុត នៃចំនួនប្រជាជនសរុបនៅក្នុងភូមិតែមួយ ដើម្បីស្វែងយល់ស៊ីជម្រៅពីទំនាក់ទំនងរវាងបំណុល និងចំណាកស្រុកនៅក្នុងភូមិ ។ ក្រុមអ្នកស្រាវជ្រាវជឿ ជាក់ថា គ្មានហេតុផលណាមួយបញ្ជាក់ថា ភូមិដែលជ្រើសរើសយកមកសិក្សាមានកម្រិតចំណាកស្រុក និងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខុសគ្នាខ្លាំងពីភូមិផ្សេងទៀតនោះទេ ។

ក្រុមអ្នកស្រាវជ្រាវចុះសិក្សា គ្រប់ផ្ទះនៅក្នុងភូមិគោលដៅ (មានចំនួនប្រមាណជា ៦០ផ្ទះ) ដែលនីតិវិធីនេះត្រូវបានផ្ទៀងផ្ទាត់ដោយរូបភាពពីផ្កាយរណប និងការអង្កេតនៅទីតាំងផ្ទាល់ ដែលអាចឱ្យអ្នកស្រាវជ្រាវធ្វើការសិក្សាទៅលើប្រជាពលរដ្ឋចំនួន ៣០គ្រួសារ ។ ស្ទើរតែគ្រប់ករណីទាំងអស់ ក្រុមអ្នកស្រាវជ្រាវគ្មានឱកាសបានសម្ភាសពលករចំណាកស្រុកដោយផ្ទាល់ទេ គឺសម្ភាសបានត្រឹមតែសមាជិកគ្រួសាររបស់ពលករចំណាកស្រុកដែលនៅផ្ទះតែប៉ុណ្ណោះ ។ នៅក្នុងបទសម្ភាសន៍ទាំងនេះ ក្រុមអ្នកស្រាវជ្រាវប្រើទម្រង់សំណួរបើកដើម្បីស្វែងយល់ពីបទពិសោធន៍ ដែលអ្នកទាំងនេះមានចំពោះការធ្វើចំណាកស្រុក និងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ មានផ្ទះមួយចំនួនដែលអ្នកស្រាវជ្រាវមិនបានធ្វើការសិក្សា ក្នុងនោះមានផ្ទះចំនួន ៨ គ្មានមនុស្សរស់នៅ ផ្ទះចំនួន ៧ ពុំមានសមាជិកណាម្នាក់ទៅធ្វើជាពលករចំណាកស្រុក និងផ្ទះចំនួន ១៥ ផ្សេងទៀត គ្មានលក្ខណៈគ្រប់គ្រាន់ដើម្បីអាចយកមកសិក្សាបាន ដោយសារកត្តាផ្សេងៗ ដែលភាគច្រើនគ្មានវត្តមានមនុស្សអាយុយ៉ាងតិច ១៨ឆ្នាំនៅផ្ទះជាដើម ។

ក្រុមអ្នកស្រាវជ្រាវទទួលបានការអនុញ្ញាតពីអ្នកចូលរួម ដើម្បីសួរសំណួរស្តីពីព័ត៌មានផ្ទាល់ខ្លួន និងសំណួរទម្រង់បើកស្តីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បំណុល និងចំណាកស្រុក នៅក្នុងចំណោមគ្រួសារសរុបចំនួន ៣០គ្រួសារ ដែលសុទ្ធសឹងតែមានឆន្ទៈចង់ពិភាក្សាជាមួយក្រុមអ្នកស្រាវជ្រាវ ។ ការស្ទង់មតិនេះរៀបចំឡើងក្នុងលក្ខណៈជាទម្រង់បើក ដើម្បីឱ្យអ្នកផ្តល់បទសម្ភាសន៍អាចបង្ហាញពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃការធ្វើចំណាកស្រុក និងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្រុមអ្នកស្រាវជ្រាវទទួលយកគ្រប់ចម្លើយសម្រាប់សំណួរទាំងអស់ ប៉ុន្តែអ្នកចូលរួមខ្លះស្នើសុំមិនឆ្លើយសំណួរមួយចំនួន ឬផ្នែកខ្លះនៃការសិក្សានេះ ។ ជាទូទៅ បទសម្ភាសន៍នីមួយៗត្រូវចំណាយពេលចន្លោះពី ២០ ទៅ ៤០នាទី ។



ផ្ទះទុកចោលរបស់គ្រួសារចំណាកស្រុកទៅប្រទេសថៃ

# ការរកឃើញនៃការសិក្សា

អ្នកភូមិទាំងអស់ដែលផ្តល់បទសម្ភាសន៍ (៣០នាក់ ក្នុងចំណោមមនុស្សសរុប ៣០នាក់) មានសមាជិកគ្រួសារយ៉ាងតិចម្នាក់បានទៅធ្វើជាពលករចំណាកស្រុកនៅក្នុងប្រទេសថៃ ។ អ្នកឆ្លើយតបទាំង ៣០នាក់នេះ បានរាយការណ៍ថា ពួកគាត់ទាំងអស់មានសមាជិកគ្រួសារសរុបចំនួន ៩២នាក់ ដែលអ្នកខ្លះមានសាច់ញាតិរហូតដល់ទៅ ៧នាក់ជាពលករចំណាកស្រុក ។ គ្រួសារភាគច្រើន ដែលផ្តល់បទសម្ភាសន៍សុទ្ធសឹងតែធ្លាប់ និងកំពុងជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (២៣គ្រួសារ ក្នុងចំណោមគ្រួសារសរុប៣០គ្រួសារ) ។ បំណុលជាមូលហេតុចម្បង ដែលនាំឱ្យគ្រួសាររបស់អ្នកទាំងនេះត្រូវធ្វើចំណាកស្រុក ។ នៅពេលសួរពីអារម្មណ៍ចំពោះបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកឆ្លើយតបភាគច្រើនបង្ហាញអារម្មណ៍ភ័យព្រួយ ។




ការភ័យខ្លាចនេះភាគច្រើន គឺជាអារម្មណ៍នៃសម្ពាធដែលត្រូវសងបំណុលត្រឡប់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ និងអារម្មណ៍ភិតភ័យដែលអាចនឹងត្រូវលក់ដីដើម្បីសងបំណុល ឬជាអារម្មណ៍ភ័យខ្លាចតិចតួចជាងនេះដូចជា បញ្ហាសុវត្ថិភាព និងសន្តិសុខរបស់សមាជិកគ្រួសារ ដែលត្រូវធ្វើជាពលករចំណាកស្រុកដោយសារបំណុល ។ មានគ្រួសារចំនួន២ ក្នុងចំណោមគ្រួសារសរុបចំនួន៣០ បានរៀបរាប់ថាពួកគាត់បានលក់ដី ដើម្បីសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រួសារជាច្រើនបានឱ្យដឹងថា ពួកគាត់ក៏មានគម្រោងលក់ដី ប៉ុន្តែដោយសារតែពុំសូវសម្បូរឱកាសការងារ ដីនៅតាមបណ្តោយព្រំដែនមានតម្លៃទាបណាស់ ។

បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ជាមូលហេតុចម្បង ដែលនាំឱ្យសមាជិកគ្រួសារត្រូវធ្វើចំណាកស្រុក ។ គ្រួសារជាច្រើន ដែលបានជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានខ្ចីប្រាក់ពីច្រើនប្រភព ក្នុងនោះមានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ ឬច្រើន ស្របពេលដែលកំពុងជំពាក់ប្រាក់អ្នកចងការប្រាក់ឯកជនផ្សេងទៀត ។

ពលករចំណាកស្រុកជាអនីតិជន ក៏ចោទជាបញ្ហាធ្ងន់ធ្ងរផងដែរ។បើតាមចម្លើយរបស់អ្នកភូមិ យ៉ាងតិចណាស់ក៏មានពលករ ៥នាក់ដែរ ដែលមានអាយុក្រោម ១៨ឆ្នាំ នៅពេលពួកគាត់ធ្វើចំណាកស្រុកលើកដំបូង ដោយក្នុងនោះមានក្មេងស្រីអាយុ១៤ឆ្នាំ ចំនួន២នាក់ ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ ក្មេងស្រីអាយុ១៦ឆ្នាំម្នាក់ និងក្មេងប្រុសអាយុ១៦ឆ្នាំម្នាក់ ។ តួលេខនេះអាចខ្ពស់ជាងនេះ ព្រោះអ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានបដិសេដមិនប្រាប់ក្រុមអ្នកស្រាវជ្រាវពីអាយុពិតរបស់ពលករនៅពេលអ្នកទាំងនោះធ្វើចំណាកស្រុកជាលើកដំបូង ឬឆ្លើយថា មិនអាចចាំបាន ។

## បញ្ហាកើតមានឡើងដោយការធ្វើចំណាកស្រុក

អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានឱ្យដឹងថា ពួកគាត់និងក្រុមគ្រួសារទទួលរងផលប៉ះពាល់ ទាំងវិជ្ជមាន និងអវិជ្ជមាន ពីការធ្វើចំណាក




ស្រុក។ ផលប៉ះពាល់ជាវិជ្ជមាន គឺសំដៅលើចំណូលពីប្រាក់ខែខ្ពស់ ព្រោះ វាបានជួយគ្រួសារឱ្យមានលទ្ធភាពសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាជាងការលើកកម្ពស់កម្រិតជីវភាពរស់នៅឱ្យប្រសើរឡើង។ ផលប៉ះពាល់អវិជ្ជមានរួមមានភាពលំបាក នៃស្ថានភាពរស់នៅសម្រាប់ពលករចំណាកស្រុកនិងគ្រួសាររបស់ពួកគាត់រស់នៅក្នុងប្រទេស ។ ជាពិសេស គ្រួសារមួយចំនួនត្រូវបានកត់សម្គាល់ថា



ក្មេងតូចៗមិនអាចទៅតាមឪពុកម្ដាយ ដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃទេ ដូច្នេះក្មេងៗទាំងនេះ ត្រូវបានទុកឱ្យនៅជាមួយជីដូនជីតាដើម្បីមើលថែ។ កង្វល់កើតចេញពីការរស់នៅឆ្ងាយពីគ្នាគឺជារឿងទូទៅ ហើយវាជាវិប្បដិសារីមួយ នៅពេលឪពុកម្ដាយត្រូវរស់នៅឆ្ងាយពីកូនរបស់ខ្លួនអស់រយៈពេលយូរ។ មានគ្រួសារមួយចំនួនតូចប៉ុណ្ណោះ បានផ្ដល់ចម្លើយ ដោយមានតែចំណុចវិជ្ជមានឬអវិជ្ជមាននៃចំណាកស្រុក ដែលនេះបង្ហាញថាគ្រួសារភាគច្រើនទទួលរងផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន ពីការធ្វើចំណាកស្រុក។ នៅពេលសាកសួរពីបញ្ហាទាក់ទងនឹងការធ្វើចំណាកស្រុកដែលពលករចំណាកស្រុកធ្លាប់ជួបប្រទះ មានតែគ្រួសារចំនួន៦ប៉ុណ្ណោះ បានឆ្លើយថាពួកគាត់គ្មានបញ្ហាអ្វីទេ ខណៈគ្រួសារចំនួន ២០ផ្សេងទៀតលើកឡើងបញ្ហាមួយ ឬច្រើនជាងនេះ ។

ការគ្មានលិខិតឆ្លងដែនគឺជាបញ្ហាដែលត្រូវបានរាយការណ៍ថាបានកើតឡើងជាញឹកញាប់ជាងគេបំផុត ហើយពលករចំណាកស្រុកទាំងនេះត្រូវបង្ខំចិត្តធ្វើចំណាកស្រុកតាមរយៈមេខ្យល់ ឬអ្នករត់ពន្ធមនុស្សដើម្បីឆ្លងដែន ។ អ្នកផ្ដល់បទសម្ភាសន៍បានរៀបរាប់ថាចំណាកស្រុកខុសច្បាប់អាចនាំឱ្យពលករត្រូវចាប់ខ្លួន ត្រូវរត់គេចពីមន្ត្រីនគរបាល ត្រូវលាក់ខ្លួនក្នុងព្រៃជាច្រើនថ្ងៃ ដោយអត់អាហារឬត្រូវចាញ់បោកមេខ្យល់ ឬថៅកែនៅក្នុងប្រទេសថៃ ។ ការធ្វើការងារខុសច្បាប់នៅក្នុងប្រទេសថៃ អាចបង្កជាបញ្ហាជាច្រើន ដូចជាការជាប់ពន្ធនាគារ និងការចាញ់បោកថៅកែថៃជាដើម ។ សម្ពាធនៃការផ្លាស់ប្ដូរការងារជាញឹកញាប់ និងការរកការងារបន្ថែមក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរបន្ថែមទៀត ដល់ពលករចំណាកស្រុកខុសច្បាប់ និងក្រុមគ្រួសាររបស់ពួកគាត់ ។

បើទោះជាពលករចំណាកស្រុកមានលិខិតឆ្លងដែនហើយក្ដី ក៏ពួកគាត់នៅតែជួបប្រទះបញ្ហាជាច្រើនដូចជា ការចាញ់បោកថៅកែថៃ ឬមេខ្យល់ជាជនជាតិខ្មែរ ការផ្លាស់ប្ដូរការងារជាញឹកញាប់ ការធ្វើការគ្មានពេលសម្រាកដើម្បីរកប្រាក់ផ្ញើមកផ្ទះ និងការមិនអាចត្រឡប់មកផ្ទះដើម្បីជួបជុំក្រុមគ្រួសារជាដើម ។

## ចំណាកស្រុក និងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រួសារជាច្រើនបានរៀបរាប់ពីមូលហេតុសំខាន់ផ្សេងៗគ្នាក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ មូលហេតុទាំងនេះត្រូវបានបែងចែកទៅតាមប្រភេទដូចជា អ្នកខ្លះខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីទិញដី ឬកែលម្អដីស្រែចំការដែលមានស្រាប់ អ្នកខ្លះខ្ចីប្រាក់ដើម្បីចំណាយលើការរត់ការ ឬសោហ៊ុយដើម្បីទៅធ្វើការនៅប្រទេសថៃ ខ្លះទៀតខ្ចីប្រាក់ដើម្បីបង់ថ្លៃព្យាបាលជំងឺ និងដើម្បីសាងសង់ផ្ទះ

" ខ្ញុំធ្វើការនៅក្នុងចំការរាល់ថ្ងៃ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាដូចធ្វើការឱ្យគេ [គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ]។ បន្ទាប់ពីជំពាក់បំណុលគេហើយ រកលុយមិនដែលសល់សោះ ។"

បញ្ហាទាក់ទងនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ចម្លើយលើសពីមួយត្រូវបានរាប់បញ្ចូល, ចំនួន៖ ២១ នាក់







ក្រុមគ្រួសារដែលបានវិលត្រលប់មកប្រទេសកម្ពុជាវិញ ពីប្រទេសថៃ អំឡុងពេលការរីករាលដាលនៃជំងឺកូវីដ១៩។ (រូបថតសង់ត្រាល់)

ជាដើម។ មូលហេតុបន្ទាប់បន្សំផ្សេងទៀតមានដូចជាខ្ចីប្រាក់ដើម្បីរៀបចំពិធីមង្គលការកូន ឬដើម្បីធ្វើដើមទុនរកស៊ីជាដើម ។

អ្នកផ្ដល់បទសម្ភាសន៍ភាគច្រើន (១៧នាក់ ក្នុងចំណោម ២១នាក់) បានឱ្យដឹងថាពួកគាត់មានបញ្ហាយ៉ាងតិចចំនួនមួយ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំណែកឯអ្នកផ្សេងទៀតស្នើសុំមិនឆ្លើយ ។ បញ្ហាដែលតែងតែកើតឡើងញឹកញាប់ជាងគេ គឺអាម្មណ៍ចំពោះការគំរាមកំហែង ឬការរងសម្ពាធបន្ទាប់ពីត្រូវគេបង្ខំឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានា ដើម្បីទទួលបានឥណទាន ។ គ្រួសារខ្លះរៀបរាប់ថាពួកគាត់មានសម្ពាធនៅពេលត្រូវបញ្ជូនសមាជិកគ្រួសារឱ្យទៅធ្វើជាពលករចំណាកស្រុក ព្រោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រាប់ពួកគាត់យ៉ាងច្បាស់ថាមានតែមធ្យោបាយនេះទេ ទើបអាចទទួលបានឥណទាន ។

គ្រួសារជាច្រើនក៏បានកត់សម្គាល់ថា មន្ត្រីឥណទានធ្លាប់ដាក់សម្ពាធដល់ពួកគាត់ ដោយពេលខ្លះលើកឡើងពីលទ្ធភាពនៃការបង្ខំឱ្យលក់ទ្រព្យធានារបស់អ្នកខ្ចីប្រាក់ ដើម្បីធានាថាបំណុលត្រូវតែទូទាត់សងត្រឡប់ទៅវិញ ។ មន្ត្រីឥណទានខ្លះទៀត លើកទឹកចិត្តឱ្យអ្នកភូមិធ្វើជាពលករចំណាកស្រុក ឬទាមទារឱ្យពួកគាត់បញ្ជាក់ថាយ៉ាងតិចណាស់មានសមាជិកគ្រួសារម្នាក់បានទៅធ្វើ ការជាពលករទើបសម្រេចផ្ដល់ឥណទានឱ្យពួកគាត់ ចំណែកមន្ត្រីឥណទានខ្លះទៀតបង្គាប់ឱ្យអ្នកភូមិកុហកពីមូលហេតុនៃការប្រើប្រាស់កម្ចី ឬស្នើសុំកម្ចីបន្ថែម ។

អ្នកភូមិម្នាក់បានលើកឡើងថា មន្ត្រីឥណទានម្នាក់ជាបុគ្គលិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ បានគំរាមបង្ខំឱ្យដាក់លក់ដី ប្រសិន បើអ្នកខ្ចីប្រាក់ គ្មានលទ្ធផលសងប្រាក់កម្ចីវិញ ។ អ្នកភូមិម្នាក់ទៀតរៀបរាប់ថា មន្ត្រីឥណទានមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាបានណែនាំឱ្យពួកគាត់កុហក ពីមូលហេតុនៃការស្នើសុំឥណទានព្រោះហេតុផលពិតនៃការស្នើសុំឥណទាននេះ គឺដើម្បីសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយទៀតគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ អំពើទុច្ចរិតរបស់បុគ្គលជាមន្ត្រីឥណទានទាំងនេះគឺដូចទៅនឹងលទ្ធផលនៃការសិក្សារួមគ្នារបស់អង្គការលីកាដូ និងសមាគមធាងត្នោតកន្លងមក ដែលជាថ្មីម្តងទៀតបង្ហាញថា បើទោះបីជាមានគោលការណ៍កម្រិតស្ថាប័ន ដែលហាមឃាត់មន្ត្រីឥណទានមិនឱ្យប្រព្រឹត្តអាកប្បកិរិយាមិនសមរម្យណាមួយក្តី ក៏ការអនុវត្តជាក់ស្តែងនៃគោលការណ៍នេះនៅមានចន្លោះប្រហោង ។

"ផលប្រយោជន៍បានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន
តិច តែព្រួយបារម្ភខ្លាំង"

លទ្ធផលនៃការសិក្សានេះ ដូចគ្នាទៅនឹងលទ្ធផលនៃការសិក្សាមុនៗ ដែលបង្ហាញថាបំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាកត្តាជួយជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាជាច្រើន ត្រូវធ្វើជាពលករចំណាកស្រុកទៅប្រទេសថៃ ដោយរួមមានទាំងការធ្វើចំណាកស្រុកខុសច្បាប់ ដែលមានហានិភ័យខ្ពស់ និងអាចធ្វើឱ្យពលករធ្លាក់ខ្លួនក្នុងហានិភ័យខ្ពស់នៃការរងគ្រោះពីការរំលោភបំពាន។ អារម្មណ៍ភ័យខ្លាច និងការគំរាមកំហែងគឺផ្ទុយស្រឡះពីគោលបំណងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់អ្នកខ្ចីប្រាក់ ។ ពេលខ្លះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន តម្រូវ ឬលើកទឹកចិត្តឱ្យ អតិថិជនរបស់ខ្លួនធ្វើចំណាកស្រុក មុនពេលសម្រេចផ្តល់ប្រាក់កម្ចី និងនៅក្នុងករណីខ្លះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជំរុញឱ្យគ្រួសារបញ្ជូនសមាជិកគ្រួសារទៅធ្វើជាពលករចំណាកស្រុក ដើម្បីបង្កើនប្រាក់ចំណូល។ ការផ្តល់ប្រាក់កម្ចីជារូបិយវត្ថុបរទេស គឺដើម្បីធានាអះអាងថាការធ្វើចំណាកស្រុកជារឿងចាំបាច់ និងអាចទទួលមូលនិធិពីដៃគូអភិវឌ្ឍន៍បរទេសបាន ។ ការអនុវត្តបែបនេះ បានចូលរួមចំណែកបង្កើនការធ្វើចំណាកស្រុកថ្មីៗទៀត និងនៅក្នុងករណីខ្លះទៀត អាចឈានទៅដល់ការបែកបាក់គ្រួសារ និងការជួញដូរមនុស្ស ដោយរួមមានទាំងការធ្វើចំណាកស្រុករបស់អនីតិជនផងដែរ ។

ដោយសារពលករចំណាកស្រុកជាច្រើននៅពេលនេះ ត្រូវបង្ខំចិត្តត្រឡប់មកផ្ទះវិញ និងត្រូវប្រឈមមុខនឹង ស្ថានភាពសេដ្ឋកិច្ចមិនអំណោយផល ដែលធ្លាប់បង្ខំឱ្យពួកគាត់ សម្រេចចិត្តធ្វើការចំណាកស្រុកជាលើកដំបូង និងការទទួលបន្ទុកដ៏ធ្ងន់ធ្ងរនៃបំណុលមីក្រូហិរញ្ញវត្ថុផងនោះ យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម្ចាស់ជំនួយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងអាចពិចារណាចាត់វិធានការបន្ទាន់បន្ថែមទៀតដើម្បីការពារអ្នកខ្ចីប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលវិធានការទាំងនេះរួមមាន៖

**១. ការវាយតម្លៃឡើងវិញនូវការផ្តល់ និងការគាំទ្រកម្ចីជារូបិយវត្ថុបាតរបស់ប្រទេសថៃ ដល់អ្នកខ្ចីប្រាក់ជាជនជាតិខ្មែរ និងធ្វើការសើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ ថាតើមីក្រូឥណទានទាំងនេះបានរួមចំណែកក្នុងការបង្កើតឱ្យមានចំណាកស្រុកដែលប្រឈមនឹងគ្រោះថ្នាក់ ឬការរំលោភសិទ្ធិមនុស្សផ្សេងទៀត ឬយ៉ាងណា ។**

**២. ការផ្អាកសងបំណុលមីក្រូហិរញ្ញវត្ថុ និងការប្រាក់ទាំងអស់យ៉ាងតិចបំផុតរយៈពេលបីខែ ដោយអាចពន្យាពេលលើសពីនេះ ដល់អ្នកខ្ចីប្រាក់ទាំងអស់ ។**

**៣. ការប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លី ដែលកំពុងកាន់កាប់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅម្ចាស់ដើមវិញ ដើម្បីធានាថាគ្មានការលក់ដីដោយបង្ខំកើតឡើង ដោយសារតែផលប៉ះពាល់នៃវីរុសកូវីដ១៩ ។**

**៤. ការបង្កើតកម្មវិធីសម្រាលបន្ទុកបំណុលដូចជាកម្មវិធីលើកលែងបំណុល ដែលអាចជួយសម្រាលបន្ទុកដល់ពលករចំណាកស្រុកដែលទើបតែត្រឡប់មកស្រុកកំណើតវិញនាពេលថ្មីៗនេះ ។**

# ឧបសម្ព័ន្ធទី១ ៖ ការផ្តល់មូលនិធិដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាជារូបិយវត្ថុបាតរបស់ប្រទេសថៃ

មូលនិធិ The Microfinance Enhancement Facility ត្រូវបានបង្កើតឡើងដោយធនាគាររបស់រដ្ឋាភិបាលអាឡឺម៉ង់ ឈ្មោះថា KFW Entwicklungsbank (KFW) នៅក្នុងឆ្នាំ២០០៩ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ដែលជាសមាជិកមួយរបស់ធនាគារពិភពលោក។ មូលនិធិនេះ បញ្ជាក់ដោយខ្លួនឯងថា "ខ្លួនមានគោលបំណងគាំទ្រការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិបុលភាពសកលតាមរយៈការផ្តល់ហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍បន្ថែមដល់មីក្រូសហគ្រាស តាមរយៈគ្រឹះស្ថានដែលមានលក្ខណៈសម្បត្តិពេញលេញ ។" មូលនិធិនេះគ្រប់គ្រងដោយក្រុមហ៊ុនវិនិយោគឯកជនចំនួនបួន គឺ BlueOrchard Finance AG , Incofin Investment Management, responsAbility Investments AG, និង Symbiotics SA ។

អ្នកវិនិយោគរបស់មូលនិធិនេះ រួមមានទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត (SIDA), ប្រទេសអូទ្រីស (OeOB), ប្រទេសហូឡង់ (FMO) និង ប្រទេស អាឡឺម៉ង់ (BMZ) ព្រមទាំងស្ថាប័នមួយចំនួនផ្សេងទៀត ដូចជា IFC ធនាគារវិនិយោគរបស់សហភាពអឺរ៉ុប និងមូលនិធិសម្រាប់អភិវឌ្ឍន៍អន្តរជាតិហៅកាត់ថា OPEC ។

បើយោងទៅតាមរបាយការណ៍របស់មូលនិធិ MEF បានឱ្យដឹងថាមូលនិធិនេះ បានវិនិយោគទឹកប្រាក់ចំនួន ៦១.៨លានដុល្លាសហរដ្ឋអាមេរិក នៅក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា។ របាយការណ៍បញ្ជាក់ថា ទឹកប្រាក់ចំនួន ៣០.៤លានដុល្លាសហរដ្ឋអាមេរិកត្រូវបានវិនិយោគជារូបិយវត្ថុបាតរបស់ប្រទេសថៃ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនបីគឺ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករចំនួន ១៦លានដុល្លាសហរដ្ឋអាមេរិក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូអិលស៊ី (LOLC) ចំនួន៣.៣លានដុល្លាសហរដ្ឋអាមេរិក និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ១១.១លានដុល្លាសហរដ្ឋអាមេរិក ៕




| Notes | A Shares |
| --- | --- |
| Private investors | KfW<br>Private investors |
| **B Shares** | **C Shares** |
| KfW | German Federal Ministry for Economic Cooperation (BMZ) |
| International Finance Corporation (IFC) | Swedish International Development Cooperation Agency (SIDA) |
| Development Bank of Austria (OeEB) | Development Bank of Austria (OeEB) |
| European Investment Bank (EIB) | **Targeted-C Shares** |
| OPEC Fund for International Development (OFID) | German Federal Ministry for Economic Cooperation (BMZ) |
| FMO | |

MICROFINANCE INVESTMENT PORTFOLIO as of 31 December 2019

| Country | Region | Name of MFI | Investment Advisor | Currency of Investment | Portfolio Equiv. USD M | New investments in Q4 2019 USD M | First Disb. | Last Maturity |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| Albania | EECAU | JSC Fondi BESA Albania | SY | EUR | [illegible] | | 09/11/2018 | 09/11/2021 |
| | | Letshego Botswana | IN | BWP | $15.0 | $5.1 | 31/07/2018 | 28/12/2022 |
| Burkina Faso | SSA | Fidelis | rA | EUR | $0.6 | | 26/01/2018 | 27/01/2020 |
| Cambodia | EAP | Amret Co Limited | IN | USD | $11.8 | | 05/04/2017 | 05/03/2021 |
| | | First Finance Cambodia | SY | USD | $2.0 | | 25/04/2019 | 25/04/2023 |
| | | Hattha Kaksekar | BO | THB | $16.0 | | 12/04/2018 | 10/05/2022 |
| | | Kredit Microfinance | rA | USD | $1.0 | | 18/06/2018 | 18/06/2020 |
| | | LOLC Cambodia | IN | THB | $3.3 | | 09/08/2018 | 09/08/2021 |
| | | LOLC Cambodia | IN | USD | $12.0 | $2.0 | 03/04/2017 | 26/11/2021 |
| | | Prasac Microfinance Institution Ltd | BO | THB | $11.1 | | 30/10/2018 | 25/04/2022 |
| | | Prasac Microfinance Institution Ltd | BO | USD | $1.7 | | 24/02/2017 | 24/02/2020 |
| | | Sathapana Limited | IN | USD | $3.0 | | 15/12/2017 | 15/12/2020 |
| China | EAP | China Foundation for Poverty Alleviation | SY | EUR | $9.1 | | 24/12/2018 | 10/12/2021 |
| | | Grassland | rA | CNY | $5.0 | | 11/10/2018 | 12/10/2021 |
| | | Microcred China | rA | CNY | [illegible] | | 05/12/2017 | 07/12/2020 |

www.licadho-cambodia.org